**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា

ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៤
ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤

សូមគោរព ៖

- ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍តាម ក្រសួង រដ្ឋលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា និង រាជធានី-ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រី មកពី អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ ជាប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍តាមក្រសួង រដ្ឋលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា និង រាជធានី-ខេត្ត និង
- អស់លោក លោកស្រី នាងកញ្ញា ជាភ្ញៀវជាតិ និង អន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមាដោយបានចូលរួមជាអធិបតីក្នុង “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៤**” ដ៏មានសារៈសំខាន់ នាពេលនេះ ។

ឆ្លៀតក្នុងឱកាសដ៏មហាវិសេសវិសាល នាពេលនេះផងដែរ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ និង អំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ដែលបានចូលរួមក្នុងវេទិកាថ្នាក់ជាតិនាពេលនេះ ។ ជាមួយគ្នានេះ ខ្ញុំក៏សូមឆ្លៀតឱកាសសម្តែងនូវការកោតសរសើរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត និង ប្រាជ្ញាស្មារតីចូលរួមចំណែកដឹកនាំ

គ្រប់គ្រង និង សម្របសម្រួលការឆ្លើយតបជាតិទូលំទូលាយ និង ពហុវិស័យប្រយុទ្ធនឹងជំងឺអេដស៍ នៅគ្រប់លំដាប់ថ្នាក់រហូតទទួលបានជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ នៅក្នុងឆ្នាំ២០១៤នេះ តាមរយៈការគ្រប់គ្រងប្រកបដោយចីរភាព នូវការធ្លាក់ចុះជាបន្តបន្ទាប់នៃការរាលដាលមេរោគអេដស៍នៅកម្ពុជា ។

ខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ២០១៤ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវប្រារព្ធឡើងជាទៀងទាត់រៀងរាល់៦ខែម្តង ។ យោងទៅតាមលទ្ធផលរបស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ នាខែវិច្ឆិកា ឆ្នាំ២០១៣ និង លើកទី១ នាខែមិថុនា ឆ្នាំ២០១៤កន្លងទៅនេះ គឺយើងទទួលបាន ៖ ទី១) សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយ៧ចំណុចក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ទី២) ការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការឆ្លើយតបមេរោគអេដស៍ និង ជំងឺអេដស៍នៅកម្ពុជាឆ្នាំ២០១២-២០១៣ ជូនអង្គការសហប្រជាជាតិ ទី៣) សេចក្តីសម្រេចជាគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការដាក់បេក្ខភាពកម្ពុជាធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំសន្និសីទអន្តរជាតិស្តីពីជំងឺអេដស៍ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៅឆ្នាំ២០១៧ ។ ក្រៅពីនោះ យើងកំពុងស្នើសុំការគាំទ្រពីរាជរដ្ឋាភិបាល ក្នុងការបង្កើនថវិកាជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង បន្តចលនាប្រភពធនធានពីខាងក្រៅជាបន្តទៅទៀត ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

យោងតាមរបៀបវារៈកិច្ចប្រជុំនាថ្ងៃនេះ គឺ យើងមកជួបជុំគ្នាដើម្បីពិនិត្យមើលឡើងវិញរួមគ្នានូវវឌ្ឍនភាព ប្រសិទ្ធភាព និង សមិទ្ធផលដែលទទួលបានពីការអនុវត្តគម្រោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍លើកទី៣ ពីឆ្នាំ២០១១-២០១៥ និង ដោយឡែកការអនុវត្តនូវគម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និង ពហុវិស័យប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០១៤ ដើម្បីឱ្យដឹងច្បាស់ថា តើយើងកំពុងទទួលបានជោគជ័យកម្រិតណា? តើយើងនៅមានចំណុចខ្វះខាតអ្វីខ្លះដែលត្រូវតែកែលម្អ ដើម្បីនាំឱ្យយើងធ្វើបានកាន់តែសុក្រិតឡើងថែមទៀតនូវ **"បច្ចុប្បន្នភាពនៃការរៀបចំសំណើគម្រោងមូលនិធិសកល"** ជាមួយនឹងការចងក្រងជាថ្មីនូវ **"គម្រោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យ ឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ លើកទី៤ ពីឆ្នាំ ២០១៦-២០២០"**។ យើងទាំងអស់គ្នាត្រូវចូលរួមធ្វើឱ្យសម្រេចបាននូវគោលដៅបីសូន្យ នាឆ្នាំ២០១៥ ២០២០ និង ២០៣០ ខាងមុខនេះ ។ ក្នុងន័យនេះ យើងត្រូវទាមទារឱ្យមាននូវ យុទ្ធសាស្ត្រ គោលនយោបាយ ធនធាន កម្រិតណា ដើម្បីឱ្យការឆ្លើយតបរបស់យើងបានសមស្របទៅនឹង

ស្ថានភាពរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ និង ស្ថានភាពប្រឈមរបស់ក្រុមគោលដៅនៅក្នុងប្រទេសកម្ពុជាយើងនេះ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ជារួម ការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍នៅលើសកលលោកក៏មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ដែរ ទោះបីជាប្រទេសមួយចំនួននៅកំពុងតែប្រឈមនឹងការរាលដាលខ្ពស់ក៏ដោយ ។ គិតត្រឹមឆ្នាំ២០១៣កន្លងទៅនេះ មានអ្នកផ្ទុកមេរោគអេដស៍ចំនួន **៣៥លាននាក់** នៅលើសកលលោក បើគិតចាប់ពីមានការរាលដាលមេរោគអេដស៍ដំបូងមក គឺមានមនុស្សប្រមាណជា **៧៨លាននាក់** ដែលបានឆ្លងមេរោគអេដស៍ ហើយក្នុងនោះ **៣៩លាននាក់** បានស្លាប់រួចទៅហើយ ។ ការឆ្លងមេរោគអេដស៍ថ្មីក៏បានធ្លាក់ចុះប្រមាណជា **៣៨%**ចាប់តាំងពីឆ្នាំ២០០១មក ហើយបើគិតត្រឹមតែក្នុងឆ្នាំ២០១៣ គឺមានអ្នកដែលបានឆ្លងមេរោគអេដស៍ថ្មីប្រមាណជា **២,១លាននាក់** ដែលកាលពីឆ្នាំ២០០១ គឺមានរហូតដល់ទៅ **៣,៤លាននាក់** ។ ការស្លាប់ដោយសារជំងឺអេដស៍ក៏បានធ្លាក់ចុះប្រមាណជា **៣៥%** ចាប់តាំងពីឆ្នាំ២០០៥មក ដែលជាឆ្នាំមានការស្លាប់ដោយសារជំងឺអេដស៍ខ្ពស់បំផុត ហើយបើគិតត្រឹមតែក្នុងឆ្នាំ២០១៣ គឺមានអ្នកស្លាប់ដោយសារជំងឺអេដស៍ ប្រមាណជា **១,៥លាននាក់** ដែលកាលពីឆ្នាំ២០០៥ គឺមានរហូតដល់ទៅ **២,៤លាននាក់** ។

ដោយឡែក ការរាលដាលមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជាគឺស្ថិតនៅក្នុងស្ថានភាពមួយដែលកំពុងតែធ្លាក់ចុះជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ១៩៩៨ ដែលមានអត្រាអ្នកផ្ទុកមេរោគអេដស៍ខ្ពស់បំផុតរហូតដល់ **១,៧%** មកនៅត្រឹមចន្លោះ **០,៧%** ទៅ **០,៦%** នឹងអាចធ្លាក់ចុះថែមទៀតរហូតដល់ **០,៤%** ក្នុងឆ្នាំ២០១៤នេះផងដែរ ។ ដូចគ្នានេះដែរ ករណីឆ្លងមេរោគអេដស៍ថ្មីក៏បានធ្លាក់ចុះជាលំដាប់ ពីខ្ពស់បំផុតចំនួន **៥.៨១៤នាក់** ក្នុងឆ្នាំ២០០០ មកនៅត្រឹមតែ **៧៨៩** នៅឆ្នាំ២០១៤ ចំណែកឯចំនួនករណីស្លាប់ដោយសារជំងឺអេដស៍ក៏បានធ្លាក់ចុះដូចគ្នាពីខ្ពស់បំផុតចំនួន **៦.៦៥៧** នៅក្នុងឆ្នាំ២០០៤ មកនៅត្រឹមតែ **៣.០៧៤** ក្នុងឆ្នាំ២០១៤នេះ គឺកើនឡើងបន្តិចបើប្រៀបធៀបទៅឆ្នាំមុនៗ ។ តាមតួលេខចុងក្រោយដែលយើងទទួលបាន ប្រទេសកម្ពុជាយើងមានអ្នកផ្ទុកមេរោគអេដស៍ចំនួន **៧២.៥៤៥នាក់** ដោយឡែកអ្នកត្រូវការឱសថប្រឆាំងមេរោគអេដស៍មានចំនួនប្រមាណជា **៥២.៦៦២នាក់** និង អ្នកដែលកំពុងទទួលសេវាព្យាបាលមានចំនួន **៤៥.៤៦៣នាក់** ។ ដូច្នេះយោងតាមព័ត៌មានស្តីពីការរាលដាលមេរោគអេដស៍នេះ យើងអាចធ្វើការសន្និដ្ឋានបានថា ប្រទេសកម្ពុជាជាប្រទេសមួយដែលទទួលបានជោគជ័យក្នុងការគ្រប់គ្រងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ទាំងស្រុង និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

នាពេលបន្តិចទៀតនេះ នឹងមានការធ្វើបទបង្ហាញមួយចំនួនស្តីពីវឌ្ឍនភាព និង សមិទ្ធផលគន្លឹះមួយចំនួនដែលយើងទាំងអស់គ្នាបានទទួលកន្លងមក នៅក្នុងឆ្នាំ២០១៤នេះ រួមជាមួយនឹងសេចក្តីព្រាងជាគោលការណ៍ស្តីពី ការរៀបចំនូវគម្រោងផែនការយុទ្ធសាស្រ្ត ជាតិទូលំទូលាយ និង ពហុវិស័យស្តីពីការឆ្លើយតបទៅនឹងមេរោគអេដស៍ និង ជំងឺអេដស៍ លើកទី៤ ពីឆ្នាំ២០១៦-២០២០ និង សេចក្តីព្រាងជាគោលការណ៍អន្តរាគមន៍គន្លឹះដើម្បី រៀបចំជាគម្រោងសំណើថវិកាទៅ គណៈកម្មាធិការមូលនិធិសកល ពីក្រុមការងារបច្ចេក ទេសនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលទាមទារជាចាំបាច់ នូវការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ក្នុងការ ពិភាក្សា ការផ្តល់យោបល់ និង អនុសាសន៍ឱ្យបានផុសផុល ដើម្បីធានាឱ្យបានថា ឯកសារជាសេចក្តីព្រាងទាំងពីរ ពិតជាបានទទួលនូវការកែលម្អឱ្យបានកាន់តែប្រសើរថែម ទៀត ដោយឆ្លុះបញ្ចាំងនូវការពិតពីការរាលដាលមេរោគអេដស៍ និង សេចក្តីត្រូវការជាអាទិ ភាព ក្នុងការឆ្លើយតបរួមជាមួយនឹងការប្រើប្រាស់នូវអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ តែចំណាយថវិកាតិច ព្រោះដូចយើងទាំងអស់គ្នាបានដឹងហើយថា ថវិកាសម្រាប់ការឆ្លើយ តបទៅនឹងជំងឺអេដស៍នៅទូទាំងសកលលោកកំពុងតែមានការធ្លាក់ចុះគួរឱ្យព្រួយបារម្ភ ។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមាន សារៈសំខាន់ណាស់ ដែលក្រុមការងារបច្ចេកទេសអាចយកទៅប្រើប្រាស់ក្នុងការរៀបចំ បញ្ចប់នូវឯកសារជាគោលការណ៍ទាំងពីរខាងលើ រួមជាមួយនឹងតម្រូវការធនធានដ៏ពិត ប្រាកដមួយ ដើម្បីឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ឱ្យកាន់តែ មានប្រសិទ្ធភាពខ្ពស់ដែលនឹងចាប់ផ្តើមចេញដំណើរពីឆ្នាំ២០១៥ខាងមុខនេះ ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការពិភាក្សា ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ច ប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នាពេលនេះ និង សូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ ឱ្យមានសុខភាពល្អ កម្លាំងមាំមួន ក្នុងការចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោង ទុក និង សូមប្រកាសបើក "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៤**" ចាប់ពីពេលនេះតទៅ ។

*សូមអរគុណ!*